# ឯកសារស្រាវជ្រាវសង្ខេប

គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា នៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

ស្តីពី

# យន្តការដោះស្រាយវិវាទដីធ្លីនៅប្រទេសកម្ពុជា


អ្នកទទួលបន្ទុកស្រាវជ្រាវ៖ កញ្ញា ហាស់ យុននារី (មន្រ្តីកម្មសិក្សាមកពីរដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា)

ចងក្រងដោយ៖ លោក ថេង ណាន (មន្រ្តីស្រាវជ្រាវ វ.ស.ក)

ជួយគាំទ្រដោយ៖ លោក បរ ហាន់ប៉ាសីត (មន្រ្តីស្រាវជ្រាវមកពីសាធារណៈរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ)



ខែកុម្ភៈ ២០១៦

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់ សភាកម្ពុជាតាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវ ទៅតាមសំណើរបសសមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើ បញ្ហាដែល កំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយ សាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារ មណ្ឌល ឬ ភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់ វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃគេហទំព័រនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារនៅក្នុងគេហទំព័រនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៦ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា


១. សេចក្តីផ្តើម..........1

២. ក្របខ័ណ្ឌច្បាប់និងការអនុវត្តន៍..........2

៣. និន្នាការវិវាទដីធ្លីតាមឆ្នាំនីមួយៗ..........3

៤. មូលហេតុនៃវិវាទដីធ្លី..........4

៥. យន្តការដោះស្រាយវិវាទដីធ្លី..........5

៦. បញ្ហាប្រឈមក្នុងការអនុវត្តន៍យន្តការដោះស្រាយវិវាទដីធ្លី..........7

៧. សេចក្តីសន្និដ្ឋាន..........9

ឯកសារយោង..........9

# យន្តការដោះស្រាយវិវាទដីធ្លីនៅប្រទេសកម្ពុជា

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាគឺជាប្រទេសកសិកម្ម ដែលមានផ្ទៃដីសម្រាប់ធ្វើកសិកម្មគ្របដណ្តប់ស្មើរតែ ២១% (ឬ ស្មើនឹង ៣,៧លានហិចតា)[1] នៃផ្ទៃដីសរុប ១៨,១លានហិចតា ពោលគឺក្នុងប្រជាជនម្នាក់ៗអាចទទួលបានដីកសិកម្ម ០,២៥ហិចតា។ នៅឆ្នាំ២០១០ ប្រជាពលរដ្ឋប្រហែលជា ៧៧.២% នៅជនបទ ដែលភាគច្រើនពឹងផ្អែកទៅលើដី និងធនធានធម្មជាតិ ដូចជាព្រៃឈើ និងការនេសាទ ដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន។[2] នៅតាមជនបទ ដីមានការពាក់ព័ន្ធយ៉ាងជ្រាលជ្រៅជាមួយនឹងវប្បធម៌និងជំនឿ និង ការរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិច និងមិនមែនជនជាតិដើម។[3]

ចាប់តាំងពីមួយទសវត្សរ៍ចុងក្រោយនេះ ដោយសារការកើនឡើងនៃតម្លៃដីធ្លី វិវាទពាក់ពន្ធ័និងកម្មសិទ្ធិដីធ្លីបានកើតឡើងរវាងប្រជាពលរដ្ឋ និងភូមិទាំងឡាយ។ ហើយមានទំនោរនៃវិវាទដីធ្លីនាំទៅដល់អំពើហឹង្សារដែលពាក់ពន្ធ័នឹងប្រជាពលរដ្ឋ អាជ្ញាធររដ្ឋាភិបាល និងក្រុមហ៊ុនឯកជនដែលទទួលបានដីសម្បទានសម្រាប់ប្រកបរបរកសិកម្ម។ ចាប់តាំងពីឆ្នាំ ១៩៨៩ ទោះបីជារដ្ឋា-ភិបាល បានព្យាយាមស្ថាបនានិងពង្រឹងការគ្រប់គ្រងដីធ្លីយ៉ាងណា ក៏នៅតែមានបញ្ហាប្រពន្ធ័ច្បាប់ និងការអនុវត្តន៍ច្បាប់។[4]

ឯកសារនេះនឹងពិនិត្យនៅលើមូលហេតុជារួមនៃវិវាទដីធ្លីនិងក្របខណ្ឌច្បាប់និងគោលនយោបាយពាក់ពន្ធ័នឹងការដោះស្រាយវិវាទធ្លីនៅប្រទេសកម្ពុជា។ ឯកសារនេះក៏នឹងកំណត់

---

[1] Geography and Map of Cambodia. October 27, 2014. http://geography.about.com/library/cia/blccambodia.htm (accessed October 27, 2014).

[2] Trading Economics. October 27, 2014. http://www.tradingeconomics.com/cambodia/rural-population-percent-of-total-population-wb-data.html (accessed October 27, 2014).

[3] (SRSG), Special Representative of the Secretary-General for human rights. Economic land concessions in Cambodia A human rights perspective. Phnom Penh: Office of High Commissoner for Human Rights (OHCHR), 2007. (របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ២០០៧៖ ការវិភាគផ្នែកសិទ្ធិមនុស្សស្តីពីមសម្បទានដីសេដ្ឋកិច្ចនិងសម្បទានផ្សេងៗទៀតនៅកម្ពុជា)

[4] Sekiguchi,M.,and N.Hatsukano.2013.Land conflicts and land registration in Cambodia. In Land and Post-conflict peace building, ed. J. Unruh and R.C. Williams. London: Earthscan. Available at: http://environmentalpeacebuilding.org/assets/Documents/LibraryItem-000-Doc-165.pdf (Accessed 16 February 2016)

អំពីបញ្ហាប្រឈមសំខាន់ៗក្នុងការអនុវត្តន៍បក្របខណ្ឌ័និងគោលនយោបាយទាំងនេះ និង ដំណោះស្រាយសម្រាប់បញ្ហាប្រឈមទាំងនេះ។

## ២. ក្របខ័ណ្ឌច្បាប់និងការអនុវត្តន៍

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ កម្មសិទ្ធឯកជនទៅលើទ្រព្យសម្បត្តិទាំងអស់ត្រូវបានបំបាត់ និងបំផ្លាញចោល។ នៅកំឡុងពេល និងក្រោយរបបនោះដប់ឆ្នាំ ដីជាកម្មសិទ្ធរបស់រដ្ឋ និងមិនមានកម្មសិទ្ធករទៅលើដីធ្លីឡើយ។ រហូតដល់ឆ្នាំ១៩៩២ សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានជាកម្មសិទ្ធ និងការផ្ទេរដីធ្លីត្រូវបានទទួលស្គាល់តាមរយៈច្បាប់ភូមិបាលដែលបានអនុ ម័តនៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២[5] និងតាមរយៈការអនុម័តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលមានចែងនៅក្នុងមាត្រា៤៤។[6] សិទ្ធិជាកម្មសិទ្ធទៅលើដីធ្លីដែលមានមុនឆ្នាំ១៩៧៩មិនត្រូវបានទទួលស្គាល់ឡើយ។[7]

ដោយបានទទួលស្គាល់ពីតម្រូវការដើម្បីធ្វើឲ្យប្រសើរឡើងនូវការគ្រប់ដីនៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលបានបង្កើតកម្មវិធីកំណែទម្រង់ដីធ្លី។ កម្មវិធីកំណែទម្រង់ដីធ្លីរបស់រាជរដ្ឋាភិបាលផ្តោតលើការពង្រឹងប្រព័ន្ធគ្រប់គ្រងលើការបែងចែក និងការប្រើប្រាស់ដី ធានានូវសុវត្ថិភាពនៃកម្មសិទ្ធដីធ្លី ។

ច្បាប់ភូមិបានឆ្នាំ១៩៩២ ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១[8] និង អនុក្រិត្យលេខ១៤៦ស្តីពីដីសម្បទាន សេដ្ឋកិច្ច ចេញនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥គឺជាឯកសារ

---

[5] ច្បាប់ភូមិបាល ១៩៩២ មាត្រា ២

[6] រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រ កម្ពុជា ១៩៩៣ មាត្រា ៤៤៖ *ជនណាក៏ដោយ ជាបុគ្គលក្តី ជាសមូសភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់។ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។*

[7] ច្បាប់ភូមិបាល ២០០១ មាត្រា ៧

[8] បច្ចុប្បន្នគឺជាច្បាប់ភូមិបាល ២០០១

គតិយុត្តចំបងដែលគ្រប់គ្រង ទៅលើដីសម្បទាន សេដ្ឋកិច្ចនៅកម្ពុជា។ ច្បាប់ភូមិបាល២០០១ អនុញ្ញាតឲ្យធ្វើសម្បទានដីសម្រាប់សេដ្ឋកិច្ច ឬ សង្គមកិច្ច។[9]

## ៣. និន្នាការវិវាទដីធ្លីតាមឆ្នាំនីមួយៗ

ទោះបីជាមានការការពារពីក្របខណ្ឌច្បាប់មួយចំនួនក៏ដោយ កាលពីទសវត្សកន្លងទៅនេះ ករណីដីមានវិវាទមានការកើនឡើងគួរឲ្យកត់សម្គាល់។ ក្នុងអំឡុងពេល២ឆ្នាំគឺឆ្នាំ២០០០ និង ២០០១ មានករណីវិវាទដីធ្លី តែមួយករណីប៉ុណ្ណោះក្នុងឆ្នាំនីមួយៗ ហើយចាប់តាំងពីឆ្នាំនោះមក ករណីវិវាទដីធ្លីមានសភាពឡើងចុះ ដែលចំណុចខ្ពស់ជាងគេគឺបិតក្នុងឆ្នាំ២០១២ មានចំនួនរហូតដល់៣៦ ករណី ប៉ុន្តែនៅឆ្នាំ២០១៤ មានការធ្លាក់ចុះមកវិញត្រឹមតែ ២៣ ករណីប៉ុណ្ណោះ។ មកទល់ពេលនេះ ពុំមានការសិក្សាស្រាវជ្រាវណាមួយបង្ហាញពីមូលហេតុនៃការប្រែប្រួលនិន្នាការនៃចំនួនវិវាទដីធ្លីនោះទេ។ គិតមកដល់ឆ្នាំ២០១៤ ចំនួនសរុបវិវាទដីធ្លីមាន ៣៥២ ករណី ដែលមាន ៦៨ ករណីត្រូវបានដោះស្រាយ ១៤ ករណីត្រូវបានបោះបង់ និង នៅសល់ ២៧០ ករណីស្មើឬ៧៧ភាគរយមិនទាន់ត្រូវបានដោះស្រាយ។[10]




ប្រភព: វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ការវិភាគស្ថិតិស្តីពីវិវាទដីធ្លីនៅកម្ពុជាឆ្នាំ២០១៤

[9] ច្បាប់ភូមិបាល ២០០១ មាត្រា ៥៩

[10] http://www.ngoforum.org.kh/administrator/components/com_ngoforum/files/00ad824b8515dd9cf8e898bb13f980e5-Layout-Land-dispute-report-2014-Eng.pdf.p.8, accessed date: 9 Feb, 2016

សូមបញ្ជាក់ថា ក្រុមអ្នកស្រាវជ្រាវបានសម្រេចចិត្តប្រើប្រាស់ទិន្នន័យរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាដើម្បីមកធ្វើការសិក្សានេះដោយសារតែក្រុមស្រាវជួបការលំបាកក្នុងការទទួលបានទិន្នន័យពីរដ្ឋាភិបាលនិងប្រភពផ្សេងៗទៀត។ ដូច្នេះ ទិន្នន័យអំពីចំនួនវិវាទដីធ្លីប្រចាំឆ្នាំអាចខុសគ្នាដោយសារតែការប្រើប្រាស់វិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យក្នុងការប្រមូលទិន្នន័យផ្សេងគ្នា។

## ៤. មូលហេតុនៃវិវាទដីធ្លី

យោងទៅលើរបាយការណ៍មួយចំនួន មូលហេតុចម្បងនៃវិវាទដីធ្លីនៅកម្ពុជា រួមមាន ក្របខណ្ឌច្បាប់មិនច្បាស់លាស់ ភាពទន់ខ្សោយរបស់ស្ថាប័នពាក់ព័ន្ធ ប្រជាជនខ្វះខាតឯកសារកម្មសិទ្ធដីធ្លី អាជ្ញាធរមានភាពមិនច្បាស់លាស់លើបន្ទាត់ព្រំដែនរវាងដីសម្បទាន និងការខ្វះខាតភាពច្បាស់លាស់ទាក់ទងនឹងដីសាធារណៈ ឬដីឯកជនរបស់រដ្ឋ និងដីសហគមន៍។[11] ការសិក្សាផ្សេងមួយទៀតរបស់វេទិកាអង្គកាមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាបានរកឃើញថា គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដីសម្បទានសេដ្ឋកិច្ចដែលពុំបានសិក្សាឲ្យបានត្រឹមត្រូវ និងគ្មានការពិភាក្សាជាសាធារណៈគឺជាមូលហេតុនាំឲ្យមានវិវាទដីធ្លី។[12]

[11] Sithan Phann, Royal University of Agriculture "Land Conflict Resolution through Cadastral Commission" http://www.forum-urban-futures.net/files/Sithan_Land%20Conflict%20and%20Conflict%20Resolution.pdf (Accessed 16 February 2016)

[12] NGO Forum on Cambodia, Research Advocacy Communication Center (RACC) "Statistical Analysis of Land Disputes in Cambodia 2014 http://www.ngoforum.org.kh/administrator/components/com_ngoforum/files/00ad824b8515dd9cf8e898bb13f980e5-Layout-Land-dispute-report-2014-Kh.pdf (Accessed 16 February 2016)




<u>មូលហេតុនៃវិវាទដីធ្លី</u>

**ប្រភព៖** វេទិការនៃអង្គការមិនមែនរដ្ឋាភិបាល (NGO Forum on Cambodia)

## ៥. យន្តការដោះស្រាយវិវាទដីធ្លី

មានយន្តការផ្លូវការចំនួនប្រាំក្នុងការដោះស្រាយវិវាទទាក់ទងនឹងដីធ្លីនៅកម្ពុជា៖ ១) ក្រុមប្រឹក្សាឃុំសង្កាត់ ២) គណៈកម្មការរដ្ឋបាល ៣) គណៈកម្មការសុរិយោដី ៤) អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី និង ៥) តុលាការ។

៥.១ ក្រុមប្រឹក្សាឃុំសង្កាត់គ្រាន់តែមានតួនាទីផ្សះផ្សាមតិខ្វែងគ្នាក្នុងចំណោមប្រជាពលរដ្ឋ ប៉ុន្តែមិនធ្វើការសម្រេចចិត្តទេ។[13]

[13] អនុក្រិត្យ ឆ្នាំ២០០២ លេខ ២២ ស្តីពី ការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ថ្ងៃទី ២៥ ខែមិនា ឆ្នាំ២០០២ មាត្រា ៦១

៥.២ គណៈកម្មការរដ្ឋបាលត្រូវបានបង្កើតឡើងសម្រាប់គ្រប់ផ្នែកទាំងអស់ដែលស្ថិតនៅក្រោមកម្មវិធីចុះបញ្ជីដីជាប្រព័ន្ធ ហើយគណៈកម្មការនេះគឺជាកន្លែងដោះស្រាយជម្លោះដំបូងសម្រាប់ជម្លោះទាំងឡាយណាដែលកើតឡើងកំឡុងពេលដំណើរការចុះបញ្ជីដី។គណៈកម្មការរដ្ឋបាល មិនមានអំណាចចេញសេចក្តីសម្រេចទេ គឺគ្រាន់អាចផ្តល់ជាជំនួយដល់ភាគីវិវាទក្នុងការដោះស្រាយជម្លោះប៉ុណ្ណោះ។[14] ប្រសិនបើគណៈកម្មការរដ្ឋបាលមិនអាចដោះស្រាយជម្លោះបានទេ ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដី។ តាមច្បាប់ភូមិបាលឆ្នាំ២០០១ តម្រូវឲ្យជម្លោះលើបញ្ហាដីដែលមិនបានចុះបញ្ជី ត្រូវដាក់ទៅគណៈកម្មការសុរិយោដីដើម្បីធ្វើការស៊ើបអង្កេត និងដោះស្រាយ ក៏ប៉ុន្តែ ប្រសិនបើភាគីជម្លោះនៅតែមិនពេញចិត្តគេអាចដាក់ពាក្យបណ្តឹងទៅតុលាការ។[15]

៥.៣ គណៈកម្មការសុរិយោទទួលខុសត្រូវដោះស្រាយជម្លោះលើបញ្ហាដីដែលមិនបានចុះបញ្ជីដែលកើតឡើងខាងក្រៅតំបន់ដែលត្រូវធ្វើការវិនិច្ឆ័យ នៅក្នុងគម្រោងនៃការចុះបញ្ជីដីជាប្រព័ន្ធ និងជម្លោះដែលកើតឡើងក្នុងកំឡុងពេលធ្វើការវិនិច្ឆ័យ និងដែលមិនអាចដោះស្រាយបានដោយគណៈកម្មការរដ្ឋបាល។[16] គណៈកម្មការសុរិយោដីរួមមានគណៈកម្មការសុរិយោដីថ្នាក់ជាតិ គណៈកម្មការសុរិយោដីខេត្តក្រុងនៅក្នុង២៤ខេត្តក្រុង និងគណៈកម្មការសុរិយោដីស្រុកខណ្ឌនៅទូទាំង ១៩៤ស្រុកខណ្ឌ។[17] គណៈកម្មការសុរិយោដីស្រុកខណ្ឌមានសិទ្ធិត្រឹមតែជួយធ្វើការសម្រុះសម្រួល ហើយចំពោះករណីដែលមិនមានការស្រុះស្រួលគ្នាទេ ករណីនោះនឹងត្រូវបញ្ជូនទៅគណៈកម្មការថ្នាក់ខេត្ត។ ប្រសិនបើករណីនោះមិនអាចដោះស្រាយបាននៅថ្នាក់ខេត្តទៀត ករណីនោះនឹងត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិដែលមានអំណាចចេញសេចក្តីសម្រេច។[18]

---

[14] សមាសភាព និងតួនាទីភារកិច្ចនៃគណៈកម្មការរដ្ឋបាល មានចែងនៅក្នុងអនុក្រិត្យ លេខ ៤៦ ស្តីពី នីតិវិធីនៃសាងសង់ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២

[15] ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ៤៧

[16] ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ៤៧

[17] ផែនការយុត្តិសាស្ត្រ ឆ្នាំ ២០០៩-២០១៣ របស់រាជរដ្ឋាភិបាល កម្ពុជា ទំព័រ ៩ និង នៅក្នុងគេហទំព័រនេះ http://www.kh.undp.org/content/cambodia/en/home/operations/projects/democratic_governance/association-of-councils-enhanced-services/

[18] អនុក្រិត្យ ឆ្នាំ ២០០២ លេខ ៤៧ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី មាត្រា ១៩

គណៈកម្មការសុរិយោដីពុំមានយុត្តាធិការលើជម្លោះដីធ្លីដែលពាក់ពន្ធ័នឹងដីដែលបានចុះបញ្ជីរួចហើយនោះទេ ព្រោះករណីនេះ គឺជាសមត្ថកិច្ច របស់តុលាការត្រូវដោះស្រាយ។ រាល់ជម្លោះពាក់ពន្ធ័នឹងកិច្ចសន្យា ឬជាមរតកត្រូវតែបញ្ជូនទៅតុលាការ ដោយមិនគិតថាដីនោះបានចុះបញ្ជីឬក៏មិនបានចុះបញ្ជីនោះទេ។[19]

៥.៤ នៅខែកុម្ភៈ ឆ្នាំ ២០០៦ អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី ត្រូវបានបង្កើតឡើងដោយរាជក្រិត្យ។[20] អាជ្ញាធរនេះមានភារកិច្ចដោះស្រាយបណ្ដឹងដែលពាក់ព័ន្ធនឹងដីធ្លីទាំងឡាយ ដែលហួសពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងទទួលពាក្យបណ្ដឹងទាក់ទងនឹងវិវាទដីធ្លីពីទូទាំងប្រទេស។

៥.៥ ក្នុងករណីដែលមានការមិនពេញចិត្តនឹងលទ្ធផលនោះទេ ភាគីជម្លោះអាចធ្វើការប្ដឹងទៅតុលាការក្នុងរយៈពេល ៣០ថ្ងៃ។[21]

## ៦. បញ្ហាប្រឈមក្នុងការអនុវត្តន៍យន្តការដោះស្រាយវិវាទដីធ្លី

នៅពេល អនុវត្តយន្តការដែលបានរៀបរាប់ខាងលើ គឺមានជួបប្រទះនូវបញ្ហាប្រឈមដោយសារកត្តាមួយចំនួនៈ ទី១ គឺខ្វះភាពច្បាស់លាស់លើដែនសមត្ថកិច្ចនៃយន្តការនីមួយៗ ដែលបណ្ដាមកពីស្ថាប័នដោះស្រាយវិវាទមានច្រើនដំណាក់កាល ដែលជាហេតុនាំឲ្យមានការភាន់ច្រលំដល់អ្នកប្ដឹងតវ៉ា។[22] ចំណែកឯកត្តាផ្សេងទៀតរួមមានការទទួលបាននូវយន្តការដោះស្រាយនៅមានលក្ខណៈខ្សោយសម្រាប់បុគ្គល និងសហគមន៍ដែលមានវិវាទ ចំណាយពេលលើផ្នែករដ្ឋបាល បន្ទុកលើនីតិវិធី និងចំណាយថវិកា ដែលជាប់ពាក់ព័ន្ធទៅនឹងការដាក់ពាក្យ

---

[19] ក្រសួងមហាផ្ទៃ និង ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ សារាចរអន្តរក្រសួង ចុះថ្ងៃទី៣១ ឧសភា ឆ្នាំ២០១១ ស្ដីពីវិធានការការពារជាបណ្ដោះអាសន្ននូវដីដែលសហគមន៍ជនជាតិដើមភាគតិចស្នើសុំចុះបញ្ជី ក្នុងពេលរងចាំចុះបញ្ជីដីនោះជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ត្រូវបានបញ្ចប់តាមនីតិវិធី។

[20] ព្រះរាជក្រិត្យ ចុះថ្ងៃទី ២៦ គុម្ភៈ ឆ្នាំ ២០០៦ ស្ដីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី កំនត់សមាសភាពនៃអាជ្ញាធរនេះដូចជាតំណាងនាយករដ្ឋមន្ត្រី ជាប្រធាន រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ជាអនុប្រធានទី១ ដែលមានសមាជិកមកពីក្រសួងធំៗផ្សេងទៀត និងតំណាងមកពីនគបាល និងកំលាំងប្រដាប់អាវុធ។

[21] អនុក្រិត្យ ឆ្នាំ ២០០២ លេខ ៤៧ ស្ដីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី មាត្រា ២ និង ៣

[22] Mark Grimsditch and Nicolas Henderson, 'Untitled: Tenure Security and Inequality in the Cambodian Land Sector,' Bridges Across Borders Cambodia, Centre for Housing Rights and Evictions (COHRE), Jesuit Refugee Service (2009), http://bit.ly/1jFVjaJ.

បណ្តឹង។ ខណៈដែលគ្មានតម្លៃជាផ្លូវការចំពោះចំណាយលើការប្តឹងទៅតុលាការ ចំណាយសោហ៊ុយលើការធ្វើដំណើរក្នុងការរត់ការ ការខាតបង់ប្រាក់ឈ្នួលពីការឈប់មកធ្វើបណ្តឹង និងខ្វះការគាំទ្រផ្នែកច្បាប់ ដែលជារឿយៗធ្វើឲ្យអ្នកប្តឹងមិនស្វែងរកដំណោះស្រាយមុនស្ថាប័នដោះស្រាយវិវាទ។ លើសពីនេះ អ្នកប្តឹងបានរាយការណ៍ថាការចេញសេចក្តីសម្រេចដោយស្ថាប័នដោះស្រាយវិវាទទាំងឡាយនោះគឺមានលក្ខណៈមិនស៊ីសង្វាក់គ្នាហើយស្ថិតនៅក្រោមសម្ពាធនយោបាយ។[23] បន្ថែមពីនេះ ភាពគ្មានឯករាជ្យ ក្នុងតុលាការ បានរួមចំណែកធ្វើឲ្យគ្មានភាពជឿជាក់ក្នុងប្រព័ន្ធដោះស្រាយវិវាទក្នុងចំណោមអ្នកដែលមានវិវាទដីធ្លី។[24] បើយោងទៅតាមការលើកឡើងរបស់ World Bank Centre for Advance Study and GTZ, គណកម្មការសុរិយោដីមានកំណត់ត្រាល្អលើការដោះស្រាយវិវាទមួយផ្នែកតូច ហើយគណកម្មការសុរិយោដីជារឿយៗក៏មានភាពលំបាកក្នុងការដោះស្រាយករណីវិវាទដែលមានលក្ខណៈស្មុគ-ស្មាញដែលមានភាគីពាក់ព័ន្ធច្រើន និងភាគីដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល ឬយោធា។[25] លើសពីនេះទៅទៀត របាយការណ៍ដដែលក៏បានបង្ហាញថាករណីដែលឈានមកដល់តុលាការរបស់គណកម្មការសុរិយោដី ភាគីដែលទន់ខ្សោយអាច នឹងបោះបង់ការប្តឹងរបស់ខ្លួនដោយសារការខ្វះជំនឿក្នុងដំណើរការនៃការប្តឹង និងលទ្ធផលដែលសម្រេចដោយតុលា-ការ។ ការសិក្សាមួយផ្សេងទៀតរបស់ធនាគារពិភពលោកបង្ហាញថាប្រជាជនដែលជាប់ពាក់ព័ន្ធក្នុងវិវាទដីធ្លី បានបោះបង់ការប្តឹងពីព្រោះតែស្ថាប័នយុត្តិធម៌ដូចជាគណកម្មការសុរិយោដី ឬ តុលាការត្រូវគេយល់ថាមានការចំណាយខ្ពស់ ប្រើពេលវេលាយូរ និងលំអៀងទៅកាន់ភាគីអ្នកមាន។[26]

---

[23] (SR), U. N. (2012). *A Human Rights Analysis of Economic and Other Land Concessions in Cambodia, Advanced Version. Available at: http://bit.ly/17FL8bq* . Phnom Penh: A/HRC/21/63/Add.1/Rev.1.

[24] *CCHR, Briefing Note "The Failure of Land Dispute Resolution Mechanisms", July 2014*

[25] World Bank, Centre for Advanced Study and GTZ, 'Towards Institutional Justice? A Review of the Work of Cambodia's Cadastral Commission in Relation to Land Dispute Resolution,' p. xii (October 2006), http://bit.ly/1n30yAW.

[26] World Bank and Centre for Advanced Study, "Justice for the Poor? An Exploratory Study of Collective Grievances over Land Local Governance in Cambodia," p. 37, (October 2006), http://bit.ly/1jXlbZH.

## ៧. សេចក្ដីសន្និដ្ឋាន

សរុបសេចក្ដីមក ទោះបីជាកម្ពុជាបានបង្កើតនូវក្របខ័ណ្ឌច្បាប់ល្អប្រសើរសម្រាប់គ្រប់គ្រងដីធ្លី បញ្ហាវិវាទដីធ្លីនៅជាកង្វល់មួយសំខាន់។ ដូចដែលបានឃើញនិន្នាការនៃចំនួនវិវាទដីធ្លីនៅទសវត្សរ៍ចុងក្រោយនេះបានបន្តកើនឡើងគួរឲ្យកត់សំគាល់។ យន្តការសម្រាប់ដោះស្រាយវិវាទដីធ្លីអាចដោះស្រាយបញ្ហានេះបានតែមួយចំនួនប៉ុណ្ណោះ។

បញ្ហាប្រឈមទាំងនេះអាចនឹងត្រូវបានដោះស្រាយតាមរយៈការពង្រឹងសម្ថភាព និងឯករាជភាពរបស់តុលាការនិងព្រមទាំងពង្រឹងយន្តការដោះស្រាយវិវាទ លើកកម្ពស់ការយល់ដឹងនិងដល់សារធារណៈអំពីការទទួលបានយន្តការដោះស្រាយវិវាទដីធ្លី និងលើកកម្ពស់តួនាទី និងភារកិច្ចនិងការទទួលខុសត្រូវរបស់គណៈកម្មការសុរិយោដីគ្រប់លំដាប់ថ្នាក់ទូទាំងប្រទេស។

# ឯកសារយោង


(SR), United National Special Rapporteur. *A Human Rights Analysis of Economic and Other Land Concessions in Cambodia, Advanced Version. Available at: http://bit.ly/17FL8bq* . Phnom Penh: A/HRC/21/63/Add.1/Rev.1, 2012.

(SRSG), Special Representative of the Secretary-General for human rights. *Economic land concessions in Cambodia A human rights perspective.* Phnom Penh: Office of High Commissoner for Human Rights (OHCHR), 2007.

(SRSG), United Nations Representative of the Secretary General. *Land Concessions for Economic Purposes in Cambopdia. A Human Rights Perspective.* Phnom Penh: CHCHR, 2004.

*Land Law.* Phnom Penh: Royal Goverment of Cambodia (RGC), 2001.

*Sub-decree No.46 on the Procedures to Establish Cadastra Index Map and Land Register.* Phnom Penh: Royal Government of Cambodia, May 31, 2002.

*Sub-decree No. 146 on Economics Land Concession.* Phnom Penh: Royal Government of Cambodia (RGC), 12 2005.

*Land Law* . Phnom Penh: Royal Government of Cambodia, 1992.

*Constitution of the Kingdom of Cambodia.* Phnom Penh: Royal Government of Cambodia (RGC), 1993.

*Sub-decree No.22 on the Decentralization of Power, Roles and Duties to the Commune/Sangkat Councils.* Phnom Penh: Royal Government of Cambodia (RGC), March 25, 2002.

*Sub-decree No. 131 on the correction of sub-decree on Economic Land Concession .* Phnom Penh: Royal Government of Cambodia (RGC), 07 2008.

*Sub-decree No. 118 on State Land Management.* Phnom Penh: Royal Government of Cambodia (RGC), October 7, 2005.

*Sub-decree No. 47 on the Organization and Functioning of the Cadastral Commission.* Phnom Penh: Royal Government of Cambodia (RGC), May 31, 2002.

*National Strategic Development Plan 2009-2013.* n.d.

Cambodian Center of Human Rights (CCHR). *Cambodia: Land in Conflict, An Overview of Land Situation .* Phnom Penh : CCHR, 2013.

*Ministry of Agriculture, Forestry and Fisheries (MAFF) .* October 27, 2014. http://www.elc.maff.gov.kh/ (accessed October 27, 2014).

Ministry of Land Management, Urban Planning and Construction (MLMUPC),. *Mannual on Implementation of Order 01 dated on 07 May, 2012 on Measures Strengthening and Increasing Effectiveness of ELC Management: http://www.mlmupc.gov.kh/mlm/imgs/20130213%20Manual%20for%20Implementing%20Govt%20Order%2001_ENG.pdf .* Phnom Penh: Royal Government of Cambodia (RGC), 2012.

NGO Forum. *Analysis on Land Dispute Occurring in Cambodia, 2010; Availble at: http://www.sithi.org/admin/upload/media.* Phnom Penh : Research and Information Centre (RIC), 2011.

NGO Forum on Cambodia, Research Advocacy Communication Center (RACC). "Statistical Analysis of Land Disputes in Cambodia2014." Working report, Phnom Penh, 2014.

PHANN, Sithann. n.d. http://www.forum-urban-futures.net/files/Sithan_Land%20Conflict%20and%20Conflict%20Resolution.pdf (accessed February 16, 2016).

Royal Government of Cambodia (RGC), Ministry of Planning (MoP). *National Strategic Development Plan 2009-2013.* Phnom Penh: Ministry of Planning , 2010.

Sekiguchi, M.,and N.Hatsukano. "Land conflicts and land registration in Cambodia. In Land and Post-conflict peace building , ed. J. Unruh and R.C. Williams. London: Earthscan." 2013: http://environmentalpeacebuilding.org/assets/Documents/LibraryIt.

Study, World Bank and Centre for Advanced. *Justice for the Poor? An Exploratory Study of Collective Grievances over Land Local Governance in Cambodia.* World Bank, 2006.

Subedi, Surya P. *United Nations Homan Rights, Office of the High Commissioner for Human Rights (UNOHCHR).* May 11, 2012. http://www.ohchr.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=12144&LangID=E (accessed August 21, 2014).

World Bank, Centre for Advanced Study and GTZ. *Towards Institutional Justice? A Review of the Work of Cambodia's Cadastral Commission in Relation to Land Dispute Resolution.* World Bank, 2006.